## រាជបណ្ឌិត្យសភាកម្ពុជា

## វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ

*អត្ថបទស្រាវជ្រាវ*

# ទម្រង់សិល្បៈមហោរីខ្មែរ




*ដោយៈ លោកស្រី យ៉ាន់ វិភារតន៍*

*ប្រធានផ្នែកទស្សនីយភាព នៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ*

**ខែធ្នូ ឆ្នាំ២០១៨**

# ទម្រង់សិល្បៈមហោរីខ្មែរ

*ដោយៈ លោកស្រី យ៉ាន់វិការតន៍*

*ប្រធានផ្នែកទស្សនីយភាព នៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ*

**សេចក្ដីផ្ដើម**

*«មហោរី» ជាទម្រង់សិល្បៈតន្ត្រីមួយប្រភេទដែលបានបង្កើតឡើងដើម្បីប្រគំថ្វាយអាទិទេព និងបម្រើព្រះមហាក្សត្រ។ ក្រោយមកតន្ត្រីមហោរី ក៏ប្រគំសម្រាប់លើកទឹកចិត្តដល់នាម៉ឺនមន្ត្រី ដែលមានគុណបំណាច់ចំពោះប្រទេសជាតិផងដែរ ជាអាទិ៍ មានការប្រគំតន្ត្រីមហោរីលើកទឹកចិត្តកងទ័ពនៅពេលវិលត្រឡប់ពីទទួលជ័យជម្នះពីសង្គ្រាមជាដើម។*

*ក្រៅពីតន្ត្រីមហោរី ខ្មែរមានទម្រង់សិល្បៈមហោរីមួយផ្សេងទៀតគឺ «ល្ខោនមហោរី» ដែលមានអាយុកាលយូរមកហើយ។ ល្ខោនមហោរី មានការសម្ដែងជាសាច់រឿងដោយប្រើតន្ត្រី និងចម្រៀងមហោរីជាមូលដ្ឋាន មានសំនៀងតិច ស្រាលស្រទន់ ដោយមានប្រើគ្រឿងភ្លេងដេញ ដំ ផ្លុំ កូតរបស់ខ្មែរ។ វង់ភ្លេងមហោរីមានប្រភពចេញពីអ្នកចេះដឹងនៅជុំវិញព្រះរាជា ក្រោយមកតន្ត្រីមហោរី និងល្ខោនមហោរី មានការវិវឌ្ឍជាបន្តបន្ទាប់ទៅតាមស្ថានភាពរបស់ប្រទេសជាតិនិងសង្គមខ្មែរ។*

**១. វង់ភ្លេងមហោរី**

*វង់ភ្លេងមហោរី ជាប្រភេទភ្លេងមានសំនៀងស្រាលស្រទន់ មានការវិវឌ្ឍពីសម័យកាលមួយទៅសម័យកាលមួយទៀត និងខុសគ្នាទៅតាមទឹកន្ទៃង ដោយគ្មានកាលកំណត់ច្បាស់លាស់។ វង់ភ្លេងមហោរី ពីដំបូងឡើយមានឧបករណ៍ភ្លេងតែ៦ទេគឺៈ ទ្រខ្មែរ១, ចាប៉ីដងវែង១, ខ្លុយ១, ស្គរថូន១, ស្គររមនា១ និងឈិង១។ តែក្រោយមកទៀតគេបានយកឧករណ៍ភ្លេងបុរាណផ្សេងៗទៀតមកប្រគំបញ្ចូលគ្នាបង្កើតបានជាវង់ភ្លេងមានឈ្មោះខុសៗគ្នាដូចជាៈ*

- ***មហោរីពិណពាទ្យ*** *មានឧបករណ៍ភ្លេងចំនួន១១គឺៈ ទ្រខ្មែរ១, តាខេ១, រនាតដែក១, រនាតឯកតូច១,រនាតធុង១, រនាតឯកផ្ទៃឫស្សី១, គងវង់ធំ១, គងវង់តូច១, ស្គរថូន១, ស្គររមនា១ និងឈិង១។*
- ***មហោរីខ្សែ*** *មានឧបករណ៍ភ្លេងចំនួន១២គឺៈ ទ្រខ្មែរ១, តាខេ១, ខ្លុយ១, ចាប៉ី១, ទ្រអ៊ូ១, ទ្រ ឆេ១, រនាតឯកផ្ទៃឫស្សី១, រនាតធុង១, គងវង់តូច១, ស្គរថូន១, ស្គររមនា១ និងឈិង១។*

- **មហោរីព្រះរាជទ្រព្យ ឬវង់ភ្លេងប៉ីកែវ** មានឧបករណ៍ភ្លេងចំនួន១៤គឺៈ ទ្រអ៊ូ១, រនាតឯក១, រនាតធុង១, តាខេធំ១, ខ្លុយតូច១, ខ្លុយធំ១,ទ្រសោធំ១,ទ្រសោតូច១, ទ្រឆេសោ១, ចាប៉ីដងវែង១, ស្គរថូន១, ក្រាបក្បួង១, ស្គររមនា១ និងឈិង១គូ។
- **មហោរីវង់ធំ** មានឧបករណ៍ភ្លេងចំនួន១៥គឺៈ ទ្រអ៊ូ១, រនាតឯក១, រនាតធុង១, តាខេ១, តាខេធំ១,ខ្លុយតូច១, ខ្លុយធំ១, ទ្រសោធំ១, ទ្រសោតូច១, ទ្រឆេសោ១, ទ្រឆេអ៊ូ១, ស្គរថូន១, ក្រាបក្បួង១, ស្គររមនា១ និងឈិង១គូ។
- **មហោរីថ្មី** មានឧបករណ៍ភ្លេងចម្រុះគ្នាជាមួយឧបករណ៍ភ្លេងអឺរ៉ុបគឺៈ ទ្រអ៊ូ១, រនាតឯក១, រនាតធុង១, តាខេ១, តាខេធំ១, ខ្លុយតូច១, ខ្លុយធំ១, ទ្រសោធំ១, ទ្រសោតូច១, ទ្រឆេសោ១, ទ្រឆេអ៊ូ១, ស្គរថូន១, ក្រាបក្បួង១, ស្គររមនា១, ឈិង១គូ, ឃឹមតូច, ឃឹមធំ, អាក់គ័រដេអុង, ហ្គីតា, វីយូឡុង, សាក់សូ។ល។

ការប្រើប្រាស់ឧបករណ៍ភ្លេងមហោរី ខុសៗគ្នាទៅតាមតំបន់នីមួយៗដោយតំបន់ខ្លះមានប្រើឧបករណ៍ភ្លេងច្រើន តំបន់ខ្លះទៀតមានប្រើឧបករណ៍ភ្លេងតិចៗ ជួនកាលមានតែឧបករណ៍ភ្លេង ដូចជា ទ្រអ៊ូ១, ទ្រសោតូច១, ឈិង១, តាខេ១, និងអ្នកចម្រៀង។ ចំពោះបទភ្លេងទៀតសោតគេច្រើនជ្រើសរើសបទណាដែលគេពេញនិយម និងចូលចិត្តស្តាប់ មកប្រគំ។

តាមឯកសារស្រាវជ្រាវរបស់លោក ព្រឹទ្ធាចារ្យ **ពេជ្រ ទុំក្រវិល** (តន្ត្រី របាំនិងល្ខោនខ្មែរ) បានបង្ហាញថា បទភ្លេងមហោរីមានរហូតដល់ទៅ <u>៦៦៤បទ</u> សម្រាប់កំដរការសប្បាយរីករាយក្នុងពិធីគ្រួសារ ឬបុណ្យនៅតាមភូមិស្រុក ឬក៏ក្នុងពិធីជប់លៀងផ្សេងៗ។ នៅសម័យឧដុង្គ និងសម័យលង្វែក បទភ្លេងមហោរីនេះត្រូវបានព្រះមហាក្សត្រ ឱ្យគេប្រគំកម្សាន្តសប្បាយសម្រាប់ពិធីលើកទឹកចិត្តកងទ័ពនៅពេលវិលត្រឡប់ពីទទួលជ័យជម្នះពីធ្វើសង្គ្រាមវិញ។

**របៀបប្រគំភ្លេងមហោរី**

បើតាមឯកសារស្រាវជ្រាវរបស់ លោក **ហ៊ុន សារិន** សាស្ត្រាចារ្យផ្នែកតន្ត្រីបុរាណនេះ បានបញ្ជាក់ថាតាំងពីដើមរហូតមកដល់បច្ចុប្បន្ន បទភ្លេងមហោរី ប្រគំមុនគេនោះគឺបទ «អាយរ៉េត» មុនបទអ្វីៗទាំងអស់។ បទអាយរ៉េតនេះ គឺជាបទប្រចាំវង់ភ្លេងមហោរីនេះប្រគុំឡើងសម្រាប់ពិធីបួងសួង រំលឹកគុណគ្រូ ហើយប្រគំបានតែម្តងទេក្នុងការសម្តែងមួយលើក។ លក្ខណៈពិសេសមួយនៃការប្រគំបទភ្លេងមហោរី គឺគេតែងតែលេងឧបករណ៍រនាតឯកប្រគំនាំមុខគេ ប៉ុន្តែមានម្តងម្កាលគេក៏ប្រើឧបករណ៍ទ្រសោតូចប្រគំមុនគេដែរ។ ចំពោះការប្រគំភ្លេងមហោរីដែលមានបទចម្រៀងលាយជាមួយក្នុងករណីភ្លេងប្រគំមុន នោះអ្នកចម្រៀងនឹងច្រៀងបត់បែនតាមសាច់ភ្លេង។ ប៉ុន្តែបើអ្នកចម្រៀងច្រៀងមុនភ្លេង អ្នកភ្លេងត្រូវលេងបត់បែនតាមបទចម្រៀងវិញ។



រូបលេខ១. ក្រុមតន្ត្រីមហោរី




រូបលេខ២. ក្រុមតន្ត្រីមហោរីនៃនាយកដ្ឋានសិល្បៈ

## ២. ល្ខោនមហោរី

ខ្មែរមានសិល្បៈសម្បូរបែបដែលនឹកស្មានមិនដល់។ ក្រៅពីបទភ្លេង ចម្រៀង នៅមានប្រភេទល្ខោនថែមទៀត។ ជាក់ស្តែង ទម្រង់សិល្បៈមហោរីមានទាំងបទភ្លេង ចម្រៀង និងល្ខោនទៀតផងដែលគេហៅ«ល្ខោនមហោរី»។ ល្ខោនមហោរីជាទម្រង់ល្ខោនមួយបែបដែលមានសិល្បករចម្រុះស្រីប្រុស រាំផង ច្រៀងផង និយាយផង ក្នុងពេលសម្តែង និងពឹងផ្អែកទាំងស្រុងលើវង់តន្ត្រីមហោរី និងចម្រៀងមហោរី។

ក្នុងអំឡុងឆ្នាំ១៩៦៥-១៩៦៦ លោកសាស្ត្រាចារ្យ **មាស គត** លោកសាស្ត្រាចារ្យ **ឆេង ផុន** និងលោកសាស្ត្រាចារ្យ **ប៉ុល សំអឿន** ជាសាស្ត្រាចារ្យខាងវិជ្ជាល្ខោន បានលើកយកឈុតខ្លះៗនៃរឿង **ថ្មរាំ** ដែលជាស្នាដៃនិពន្ធដោយសាស្ត្រាចារ្យ **ហង់ ធុនហាក់** មករៀបរៀងជាល្ខោនមហោរី

*សម្តែងដោយលោក **ពេជ្រ ទុំក្រវិល** និងអ្នកស្រី **អ៊ុំ មន្ទា**។ ពេលនោះហើយដែលល្ខោនមហោរី ចាប់ផ្តើមមានកំណើតឡើងវិញ។ សាច់រឿងដែលមានទម្រង់ល្ខោនមហោរីមានដូចជា៖*

- *រឿង **វិប្បដិសារីនៃព្រានព្រៃ** និពន្ធដោយលោក **ពេជ្រ ទុំក្រវិល***
- *រឿង **ប្រហែសបាត់ប្រយ័ត្នគង់** និពន្ធដោយលោក **ពេជ្រ ទុំក្រវិល***
- *រឿង **មិនខ្វះទេអ្នកស្រឡាញ់យុត្តិធម៌** និពន្ធដោយលោក **ពេជ្រ ទុំក្រវិល***
- *រឿង **តេមិយកុមារ** រៀបរៀងដោយលោក **ពេជ្រ ទុំក្រវិល***
- *រឿង **សុវណ្ណសាម** រៀបរៀងដោយលោក **ពេជ្រ ទុំក្រវិល***

*ល្ខោនមហោរីមានរូបរាងឡើងវិញ និងរីកចម្រើន ក៏អាស្រ័យទៅនឹងស្ថានភាពសន្តិសុខនៃប្រទេសដែរ។ នៅពេលប្រទេសកម្ពុជាទទួលបានឯករាជ្យពីអាណានិគមបារាំង ក្រោមព្រះរាជកិច្ចដឹកនាំរបស់**ព្រះបាទព្រះនរោត្តម ស៊ីហនុ** ប្រទេសកម្ពុជាបានទទួលសុខសន្តិភាព ប្រជាជនរស់នៅបានសេចក្តីសុខ ដូច្នេះហើយវិស័យសិល្បៈល្ខោនមហោរីចាប់ផ្តើមមានជីវិតរស់ឡើងវិញ និងមានការរីកចម្រើនផងដែរ។ ប៉ុន្តែនៅឆ្នាំ១៩៧៣ ប្រទេសកម្ពុជាបានជួបបញ្ហាសង្គ្រាមផ្ទៃក្នុងរ៉ាំរ៉ៃ អូសបន្លាយរហូតដល់ឆ្នាំ១៩៧៥។ ចាប់ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ ប្រទេសកម្ពុជាបានធ្លាក់ក្នុងរបបប្រល័យពូជសាសន៍ វង់ភ្លេងមហោរី ក៏ដូចជាល្ខោនមហោរី ត្រូវបាត់បង់ ពិសេសការបាត់បង់សិល្បករ ជាបញ្ហាដែលធ្វើឱ្យសិល្បៈមហោរីត្រូវប្រឈមនឹងការបាត់បង់ធ្ងន់ធ្ងរ។*

*បច្ចុប្បន្ននេះ នៅមានល្ខោនមហោរីនៅឡើយ ហើយយើងនៅឃើញមានការសម្តែងជាសាច់រឿងមួយចំនួនដូចជា រឿង«ចាបជៀបពពិច» ដែលជាសាច់រឿងបែបល្បើកកថា និទានអំពីជាតិទី១នៃរឿង «សព្វសិទ្ធ»ជាដើម។ នាយកដ្ឋានសិល្បៈនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងសាលាបឋមសិក្សាសិល្បៈ ព្រមទាំងក្រុមសិល្បៈខ្មែរអមតៈ បានខិតខំរក្សាល្ខោនមហោរីផងដែរ។*




រូបភាពសម្តែងសិល្បៈល្ខោនមហោរីរបស់សាស្ត្រាចារ្យ ពេជ្រ ទុំក្រវិល
ក្នុងរឿង «វិប្បដិសារីនៃព្រានព្រៃ» ក្នុងទសវត្សទី៦០



រូបភាពសម្តែងល្ខោនមហោរី

## សន្និដ្ឋាន

សិល្បៈមហោរីជាសិល្បៈមួយប្រភេទដែលបានបម្រើសង្គមជាតិ និងមនុស្សជាតិខ្មែរស្ទើរតែគ្រប់ជំនាន់។ វាជាប្រភេទសិល្បៈបែបលួងលោម បំពេអារម្មណ៍ ព្រមទាំងបានបង្កប់នូវខ្លឹមសារអប់រំដល់មនុស្សនិងសង្គមទៀតផង។ បទមហោរីនីមួយៗបានបង្កប់នូវអត្ថន័យជ្រាលជ្រៅ ដោយនៅពេលបានស្តាប់ ហាក់បម្រើអារម្មណ៍ដោយឡែកៗទៅតាមកាលវេលា។ ដោយសារតែសិល្បៈ

មហោរីនេះមានបទចម្រៀងច្រើនសម្បូរបែប ធ្វើឱ្យអ្នកស្ដាប់មិនធុញទ្រាន់ដែរ។ លក្ខណៈសំខាន់ដែលធ្វើឱ្យសិល្បៈនេះនៅតែរក្សាបានគង់វង្ស គឺដោយសារបទភ្លេងមហោរី បានបញ្ជ្រាបខ្លួនទៅក្នុងផ្នែកសិល្បៈដទៃទៀត ដូចជាផ្នែករបាំ ផ្នែកល្ខោនមានគ្រប់ទម្រង់ ផ្នែកតន្ត្រី ជាដើម។ ទោះជាបែបនេះក្ដី យើងនៅតែមានក្ដីបារម្ភខ្លាចបាត់បង់នូវទម្រង់សិល្បៈមួយនេះ ដោយសារឃើញប្រជាជនខ្មែរបច្ចុប្បន្នហាក់មិនសូវនិយមចូលចិត្តសិល្បៈនេះ។ ការថែរក្សាមរតកវប្បធម៌ដ៏មានតម្លៃរបស់ដូនតាជាកាតព្វកិច្ចរបស់កូនខ្មែរគ្រប់រូប។ ក្នុងនាមជាពលរដ្ឋខ្មែរត្រូវចេះថែរក្សា គាំទ្រ និងលើកកម្ពស់ដល់សិល្បៈរបស់ដូនតាខ្លួនដើម្បីកុំឱ្យបាត់បង់។ ក្រៅពីនេះ រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួង និងស្ថាប័នពាក់ព័ន្ធគួរបំផុសមហាជនដោយឧស្សាហ៍រំលឹកបង្ហាញ ឆ្លុះបញ្ចាំងតាមរយៈរូបភាព តាមទូរទស្សន៍ឬតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដើម្បីជួយឱ្យកូនខ្មែរជំនាន់ក្រោយបានយល់ជ្រួតជ្រាបកាន់តែច្បាស់ពីតម្លៃរបស់វា និងជំរុញលើកទឹកចិត្តនិងផ្ដល់តម្លៃដល់សិល្បករខ្មែរឱ្យសាកសមទៅនឹងគុណតម្លៃរបស់ពួកគាត់ដែលបានលះបង់នៅក្នុងវិស័យនេះ។

**ឯកសារយោង**


១. សម្ដេចព្រះសង្ឃរាជ ជួន ណាត *វចនានុក្រមខ្មែរ* បោះពុម្ពលើកទី៥ ដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨ ។

២. ព្រឹទ្ធាចារ្យ ពេជ្រ ទុំក្រវិល *របាំខ្មែរ* ឧបត្ថម្ភដោយ មូលនិធិតូយ៉ូតា ឆ្នាំ២០០១។

៣. ព្រឹទ្ធាចារ្យ ពេជ្រ ទុំក្រវិល *ជីវិតគឺជាសិល្បៈ*។

៤. សាស្ត្រាចារ្យ ហ៊ុន សារិន *ស្វែងយល់សិល្បៈទស្សនីយភាពខ្មែរ* ឆ្នាំ ២០១១។

៥. ពុទ្ធសាសនបណ្ឌិត្យ អំពីលំនាំសង្ខេបនៃភ្លេងខ្មែរ ឆ្នាំ១៩៧០។

៦. ក្រសួងអប់រំ កំណាព្យខ្មែរ ឆ្នាំ១៩៨៨។

៧. គេហទំព័រ https://km.wiktionary.org

៨. គេហទំព័រ http://chanvirakedu.blogspot.com